ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ: ៤៥០០
ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤
សំណុំរឿងជំនុំជម្រះលេខ ១៣២៩
ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥
សាលក្រមលេខ ៣៩៥ ក្រ.១ "ខ" ត.ព.ព្រ.ឧ
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនាថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង០៨ ព្រឹក ដោយមានសមាសភាពដូចខាងក្រោម ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

16 Sep. 2015

### តំណាងអយ្យការ

កញ្ញា [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៥០០ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ២០១៤ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] **យ៉ាំងទីង** ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិវៀតណាម មុខរបរ មិនពិតប្រាកដ ទីកន្លែងកំណើត ស្រុកពញាឮ ខេត្តកណ្តាល មានទីលំបច្ចុប្បន្ន [redacted] សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន ជានីតិជន ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ២៦៤៥ ត.ព្រ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០១៤ ។

២.ឈ្មោះ [redacted] **យ៉ាំងគីយ** ភេទប្រុស អាយុ ៤០ឆ្នាំ ជនជាតិវៀតណាម មុខរបរ ចិញ្ចឹមត្រី ទីកន្លែងកំណើត ខេត្តកំពង់ឆ្នាំង មានទីលំបច្ចុប្បន្ន [redacted] សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន ជានីតិជន ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ២៦៤៦ ត.ព្រ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០១៤ ។

ជាប់ចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចបន្ទប់ផ្ទះគ្មានលេខ បុរីប៊ុជេស៍ ភូមិដូង មណ្ឌល៥ សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានី



Scanned with CamScanner

ភ្នំពេញ កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៤ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-លោក [redacted]វ៉េល ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១០៧៤ អ.យ.ប ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២២៧០ ដ.ជ.រ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទ

-កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៤ វេលាម៉ោង១៤និង៣០នាទី នៅចំណុចផ្ទះគ្មានលេខ បុរីប៉ិនដេស់ ភូមិដូង មណ្ឌល៥ សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ មានករណីជួញដូរគ្រឿងញៀនខុសច្បាប់ ដែលបង្ក ឡើងដោយជនជាប់ចោទឈ្មោះ [redacted] យ៉ាំងតឹយ ភេទប្រុស អាយុ៤០ឆ្នាំ និងឈ្មោះ [redacted] យ៉ាំងទឹង ភេទប្រុស អាយុ ៣៧ឆ្នាំ ។ នៅថ្ងៃកើតហេតុឈ្មោះ [redacted] យ៉ាំងតឹយ បាននាំម៉ូយទិញគ្រឿងញៀន (កម្លាំងសម្ងាត់) ទៅរង់ចាំទិញគ្រឿងញៀននៅក្នុងផ្ទះគ្មានលេខ ផ្លូវបេតុង បុរីប៉ិនដេស់ នៅពេលរង់ចាំបានមួយសន្ទុះក្រោយមក ស្រាប់តែឈ្មោះ [redacted] យ៉ាំងទឹង បានជិះម៉ូតូមួយគ្រឿងមកដល់ ហើយប្រគល់គ្រឿងញៀនដែលដាក់នៅក្នុងកាបូបស្ពាយ រួចហុចទៅឱ្យឈ្មោះ [redacted] យ៉ាំងតឹយ ដើម្បីប្រគល់ឱ្យម៉ូយដែលកម្មង់ទិញនោះ ។ នៅពេលកំពុងធ្វើសកម្មភាពជួញដូរ ក៏ត្រូវកម្លាំងសមត្ថកិច្ចចុះបង្ក្រាបធ្វើការឃាត់ខ្លួនជាក់ស្តែង រួមជាមួយវត្ថុតាងគ្រឿងញៀនចំនួន០៣ដុំ មានទម្ងន់សរុប ១០៤៩,៣៩ ក្រាម ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងទឹង បានឆ្លើយសារភាពថា៖ ខ្លួនពិតជាបានយកកាបូបពីឈ្មោះ យ៉ាង ហើយខ្លួនបានដឹងថាក្នុងកាបូបនោះមានគ្រឿងញៀន បន្ទាប់មកឈ្មោះ យ៉ាង បានឱ្យលុយខ្លួនចំនួន ម្ភៃម៉ឺនរៀល ដើម្បីឱ្យខ្លួនយកកាបូបដែលមានគ្រឿងញៀននោះ ទៅឱ្យគេ នៅចំណុចហ្វេសផ្សារព្រែកព្នៅ នៅពេលខ្លួនទៅដល់ចំណុចនោះស្រាប់តែមានឈ្មោះ តឹយ បានមកយកកាបូបពីខ្លួនរួចដើរទៅទិសខាងជើង ភ្លាមនោះក៏មានមនុស្សមួយក្រុមមកឡោមព័ទ្ធចាប់ខ្លួន រួមជាមួយនឹងឈ្មោះ តឹយ តែម្តង ។ ចំពោះបុរសដែលប្រគល់កាបូបឱ្យខ្លួន ក៏ជិះម៉ូតូតាមខ្លួនពីក្រោយដែរ ដោយបានឈប់ម៉ូតូចម្ងាយ ១០ម៉ែត្រពីខ្លួន តែគេចាប់ពុំបានទេ ។

-ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងតឹយ បានឆ្លើយសារភាពថា៖ ខ្លួនបានទាក់ទងឈ្មោះ យ៉ាង និងស្គាល់ឈ្មោះ យ៉ាង ជាងមួយឆ្នាំហើយ គឺស្គាល់តាមរយៈការទិញត្រីពីខ្លួន ហើយនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៤ ខ្លួនបានជួបជាមួយបុរសពីរនាក់ និងស្ត្រីម្នាក់ គាត់បានពឹងឱ្យខ្លួនយកឥវ៉ាន់ទៅឱ្យគេដោយប្រាប់ថាមានចំនួន ០៣ដុំ និងបានសន្យាថាឱ្យលុយខ្លួនចំនួន ១៥០ដុល្លារអាមេរិក រួចខ្លួនក៏ព្រមតាមដោយមិនទាន់បានទទួលលុយទេ ។ ពេលខ្លួនបានដើរចេញពីផ្ទះប្អូនបានចម្ងាយជិតមួយម៉ែត្រខ្លួនបានឃើញឈ្មោះ ទឹង ជិះម៉ូតូម្នាក់ឯងមានកាបូបមួយពណ៌លឿង ហើយឃើញមានមនុស្សប្រុសពីរនាក់ទៀតឈប់ជិតហ្នឹង ជិះម៉ូតូម៉ាកវីវ៉ា ពណ៌ខ្មៅ រួចខ្លួនបានទៅយកកាបូបពីឈ្មោះ ទឹង ដើម្បីយកទៅឱ្យ



Scanned with CamScanner

គេបន្ទរ លុះពេលដើរមកដល់មុខផ្ទះប្អូនខ្លួនស្រាប់តែមានមនុស្ស មកចាប់ខ្លួន រួមជាមួយឈ្មោះ ទឹង តែម្តង ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ឆ្លងតាមអង្គសវនាការនេះឃើញថាជនជាប់ចោទឈ្មោះ [redacted] យ៉ាំងទឹង ភេទប្រុស អាយុ ៣២ឆ្នាំ និងឈ្មោះ [redacted] យ៉ាំងតឺយ ភេទប្រុស អាយុ ៤០ឆ្នាំ បានឆ្លើយសារភាពពីទោសកំហុសដែលគេបានប្រព្រឹត្តនៅចំពោះមុខតុលាការអស់ហើយ ហេតុនេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ: ១០៧៨ អ.យ.ប ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥ ទុកជាបានការដដែល ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ឆ្លងតាមអង្គសវនាការនេះឃើញថា កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពពីទោសកំហុសដោយឥតលាក់លៀម នៅគ្រប់តំណាក់កាលនីតិវិធីអស់ហើយ ។ ម្យ៉ាងវិញទៀតកូនក្តីខ្លួនទាំងពីរនាក់គឺជាជនជាតិវៀតណាម ពុំចេះអក្សរខ្មែរ ហើយមានការយល់ដឹងបានតិចតួច មិនតែប៉ុណ្ណោះ កូនក្តីខ្លួនមានជីវភាពក្រីក្រពេក និងមានកូនក្នុងបន្ទុកច្រើនដែលពុំអាចទប់ទល់នឹងជីវភាពគ្រួសារបាន ទើបកូនក្តីខ្លួនឈានទៅដល់ការប្រព្រឹត្តបទល្មើស ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារឲ្យជនជាប់ សូមសុំណូមពរឲ្យតុលាការមេត្តាជួយផ្តល់ស្ថានសម្រាលទោសឲ្យកូនក្តីខ្លួនត្រឹមអប្បបរមានៃទោស ដោយក្តីអនុគ្រោះផង។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ:

-ឈ្មោះ [redacted] យ៉ាំងទឹង ភេទប្រុស អាយុ ៣២ឆ្នាំ និងឈ្មោះ [redacted] យ៉ាំងតឺយ ភេទប្រុស អាយុ ៤០ឆ្នាំ បានសុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

ក្រោយពីបានសួរដេញដោលក្នុងអង្គសវនាការ

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីកានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងរយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាងនិងពិចារណាលើសំណុំរឿងត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការ

## យល់ឃើញថា:

០១-កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៤ នៅចំណុចផ្ទះគ្មានលេខ ផ្លូវបេតុង បុរីប៊ុនជេស៍ ភូមិដូង មណ្ឌល៥ សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ មានករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មួយកើតឡើងប្រាកដមែន ។

០២-អំពើល្មើសខាងលើប្រព្រឹត្តឡើងដោយជនជាប់ចោទឈ្មោះ ង្វៀង យ៉ាំងទឹង ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិវៀតណាម និងឈ្មោះ[redacted]យ៉ាំងតឺយ ភេទប្រុស អាយុ ៤០ឆ្នាំ ជនជាតិវៀតណាម ដោយជនជាប់ចោទឈ្មោះ [redacted] យ៉ាំងតឺយ បាននាំម៉ូយទៅទិញគ្រឿងញៀននៅចំណុច ផ្ទះគ្មានលេខ ផ្លូវបេតុង បុរីប៊ុនជេស៍ ភូមិដូង មណ្ឌល៥ សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ពេលរង់ចាំបានមួយសន្ទុះក្រោយមកស្រាប់តែមានឈ្មោះ[redacted] យ៉ាំងទឹង បានជិះម៉ូតូមកដល់បានប្រគល់គ្រឿងញៀនដែលដាក់ក្នុងកាបូបស្ពាយ រួចហុចទៅឱ្យជនជាប់ចោទឈ្មោះ[redacted]យ៉ាំងតឺយ ដើម្បីឱ្យម៉ូយដែលកម្មង់

ទិញនោះ ។ នៅពេលកំពុងធ្វើសកម្មភាពជួញដូរគ្រឿងញៀន ក៏ត្រូវកម្លាំងសមត្ថកិច្ចចុះបង្ក្រាបធ្វើការឃាត់ខ្លួនជាក់ស្តែង រួមជាមួយវត្ថុតាងគ្រឿងញៀនចំនួនបីដុំ មានទម្ងន់សរុប ១០៤៩,៣៩ក្រាម ។

០៣-ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងទឹង នៅគ្រប់ដំណាក់នីតិវិធីបានឆ្លើយសារភាពថា ខ្លួនពិតជាបានធ្វើសកម្មភាព ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយខ្លួនបានទទួលគ្រឿងញៀនពីឈ្មោះ យ៉ាំង រួចបានយកគ្រឿងញៀននោះទៅឱ្យឈ្មោះ [redacted] យ៉ាំងគីយ ដើម្បីឱ្យម៉ូយបន្ត ។

ចម្លើយនេះតុលាការពិចារណាឃើញថា ពិតជាមានស៊ីសង្វាក់ទៅនឹងអង្គហេតុដែលបានកើតឡើង ជាពិសេសស៊ីសង្វាក់ទៅ និងភស្តុតាងដែលមាននៅក្នុងសំណុំរឿង ដែលអាចបញ្ជាក់ឲ្យឃើញថា ជនជាប់ចោទពិតជាចារីដែលបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ដូចការចោទប្រកាន់ប្រាកដមែន ។

០៤-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងគីយ នៅគ្រប់ដំណាក់នីតិវិធីបានឆ្លើយសារភាពថា ខ្លួនពិតជាបានធ្វើសកម្មភាព ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដោយខ្លួនបានទទួលគ្រឿងញៀនចំនួនបីដុំ ពីឈ្មោះ [redacted] យ៉ាំងទឹង ដើម្បីយកទៅឱ្យម៉ូយ ដែលគេបានសន្យាថាឱ្យលុយខ្លួនចំនួន ១៥០ ដុល្លារអាមេរិក ។

ចម្លើយនេះតុលាការពិចារណាឃើញថា ពិតជាមានស៊ីសង្វាក់ទៅនឹងអង្គហេតុដែលបានកើតឡើង ជាពិសេសស៊ីសង្វាក់ទៅ និងភស្តុតាងដែលមាននៅក្នុងសំណុំរឿង ដែលអាចបញ្ជាក់ឲ្យឃើញថា ជនជាប់ចោទពិតជាចារីដែលបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ដូចការចោទប្រកាន់ប្រាកដមែន ។

០៥-ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងទឹង និងឈ្មោះ [redacted] យ៉ាំងគីយ បានប្រព្រឹត្តអំពើទុច្ចរិតជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលបានបំពានទៅនិងនីត្យានុកូលភាពនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចែងក្នុងបញ្ញត្តិមាត្រា ៥០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

០៦-អំពើ និងសកម្មភាពរបស់ជនជាប់ចោទធ្វើអោយខូចសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងប៉ះពាល់ដល់សុខភាព និងរូបកាយរបស់ប្រជាពលរដ្ឋទូទៅដែលច្បាប់បានការពារ និងគួរឱ្យផ្តន្ទាទោស ។

០៧-ពេលធ្វើសកម្មភាពជនជាប់ចោទមានសតិបញ្ញាស្មារតីគ្រប់គ្រាន់ ប្រព្រឹត្តអំពើល្មើសច្បាប់ រហូតសម្រេចតាមបំណងរបស់ខ្លួន ហើយជានីតិជនដែលមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។

០៨-តំណាងអយ្យការប្តឹងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ដែលចំណុចនេះគប្បីតុលាការពិចារណា ។

០៩-យល់ឃើញពីបុគ្គលិកលក្ខណៈសម្បត្តិរបស់ជនជាប់ចោទបានឆ្លើយសារភាពដោយឥតលាក់លៀមពីអំពើដែលខ្លួនបានប្រព្រឹត្ត ហើយដោយជននេះជាជន ដែលគ្មានចំណេះដឹង និងមានកម្រិតជីវភាពក្រីក្រ គប្បីតុលាការពិចារណាអំពីស្ថានសម្រាលសម្រាប់ជនជាប់ចោទ។

១០-យល់ឃើញថាជនជាប់ចោទទាំងពីរនាក់ ពុំមែនជាមេក្លោង និងជាម្ចាស់គ្រឿងញៀននោះទេ គឺជនជាប់ចោទទាំងពីរនាក់គ្រាន់តែជាអន្តរការីក្នុងការជួញដូរគ្រឿងញៀននេះ ដើម្បីទទួលបាននូវកម្រៃក្នុងការផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ តែប៉ុណ្ណោះ ដែលចំណុចនេះគប្បីតុលាការពិចារណាអំពីស្ថានសម្រាលសម្រាប់ជនជាប់ចោទ។

១១-តាមលទ្ធផលនៃការគណនាអំពីវត្ថុចាប់យក ជាសារធាតុញៀនរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងទឹង និងឈ្មោះ [redacted] យ៉ាំងគីយ ប្រភេទម្សៅ ឈ្មោះ ហេរ៉ូអ៊ីន (Heroine) មានទម្ងន់ ១០៤៩,៣៩ក្រាម គុណ ៥១,៩៣ ចែក ១០០ ស្មើ ៥៤៤,៩៤ ក្រាម ។



Scanned with CamScanner

តាមលទ្ធផល ៥៨៥,៩៨ ក្រាម គឺភស្តុតាងនៅក្នុងតារាងទី១ នៃមាត្រា ៤០ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលតម្រូវឲ្យផ្តន្ទាទោសពី ២០ឆ្នាំ (ម្ភៃឆ្នាំ) ទៅ ៣០ឆ្នាំ (សាមសិបឆ្នាំ) ឬអស់មួយជីវិត និងផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ រៀល (សែសិបលានរៀល) ទៅ ១០០.០០០.០០០ រៀល (មួយរយលានរៀល) ។

១២-វត្ថុចាប់យកដែលត្រូវសមត្ថកិច្ចដកហូតពីជនជាប់ចោទ ក្រោយពេលប្រព្រឹត្តបទល្មើសរួចរួមមានៈ ទូរស័ព្ទដៃម៉ាក NOKIA ម៉ូដែល ២០៦ ចំនួន ០១ គ្រឿង ទូរស័ព្ទដៃម៉ាក NOKIA ម៉ូដែល C5-03 ចំនួន ០១ គ្រឿង ដែលវត្ថុតាងទាំងនេះមិនមែនជាវត្ថុសម្រាប់ប្រើប្រាស់ធ្វើជាមធ្យោបាយក្នុងការប្រព្រឹត្តបទល្មើសទេ ហេតុនេះគប្បីតុលាការសម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ ចំណែកឯ ស្រោមសំបុត្រពណ៌លឿងបិតស្កុតជិត មានចុះហត្ថលេខាមន្ត្រីជំនាញ និងស្នាមមេដៃជនសង្ស័យឈ្មោះ [redacted] យ៉ាំងទឹង ,ឈ្មោះ [redacted] យ៉ាំងតឺយ និងមានប្រថាប់ត្រា មន្ទីរប្រឆាំងគ្រឿងញៀន ដោយសរសេរដាក់ថាវត្ថុតាងគ្រឿងញៀនពណ៌សទម្ងន់ ១០៨៩,៣៩ (មួយពាន់សែសិបប្រាំបួន ក្បៀសសាមសិបប្រាំបួន ក្រាម) ចំនួន ០១ ឃើញថាវត្ថុទាំងនេះគឺភស្តុតាងជាក់ស្តែងដែលបង្កើតឲ្យមានបទល្មើស ហេតុនេះគប្បីតុលាការសម្រេចរឹបអូស ។

១១-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] យ៉ាំងទឹង ភេទប្រុស អាយុ ៣២ឆ្នាំ ជនជាតិវៀតណាម និងឈ្មោះ [redacted] យ៉ាំងតឺយ ភេទប្រុស អាយុ ៤០ឆ្នាំ ជនជាតិវៀតណាម ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច បន្ទប់ផ្ទះគ្មានលេខ បុរីប៉ិជេស៍ ភូមិដូង មណ្ឌល ៥ សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៤ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រាកដមែន ។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី

១-ផ្តន្ទាទោសឈ្មោះៈ

ក.[redacted] **យ៉ាំងទឹង** ភេទប្រុស អាយុ ៣២ ឆ្នាំ ជនជាតិវៀតណាម ដាក់ពន្ធនាគារកំណត់ ២៥ ឆ្នាំ (ម្ភៃប្រាំឆ្នាំ) និងពិន័យជាប្រាក់ចំនួន ៦០ ០០០ ០០០ រៀល (ហុកសិបលានរៀល) ។

ខ.[redacted] **យ៉ាំងតឺយ** ភេទប្រុស អាយុ ៤០ ឆ្នាំ ជនជាតិវៀតណាម ដាក់ពន្ធនាគារកំណត់ ២៥ ឆ្នាំ (ម្ភៃប្រាំឆ្នាំ) និងពិន័យជាប្រាក់ចំនួន ៦០ ០០០ ០០០ រៀល (ហុកសិបលានរៀល) ។

ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះគ្មានលេខ បុរីប៉ិនជេស៍ ភូមិដូង មណ្ឌល០៥ សង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ២០១៤ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-វត្ថុចាប់យកដែលត្រូវរឹបអូសមាន ៖

-ស្រោមសំបុត្រពណ៌លឿងបិតស្កុតជិត មានចុះហត្ថលេខាមន្ត្រីជំនាញ និងស្នាមមេដៃជនសង្ស័យ ឈ្មោះ [redacted] យ៉ាំងទឹង ,ឈ្មោះ [redacted] យ៉ាំងតឺយ និងមានប្រថាប់ត្រាមន្ទីរប្រឆាំងគ្រឿងញៀន ដោយសរសេរដាក់ថាវត្ថុតាងគ្រឿងញៀនពណ៌សទម្ងន់ ១០៨៩,៣៩ (មួយពាន់សែសិបប្រាំបួន ក្បៀសសាមសិបប្រាំបួនក្រាម) ចំនួន ០១ ។

៣-វត្ថុចាប់យកដែលត្រូវប្រគល់ឲ្យម្ចាស់ដើមវិញៈ

ក,ទូរស័ព្ទដៃម៉ាក NOKIA ម៉ូដែល ២០៦ ចំនួន ០១ គ្រឿង ។

ខ,ទូរស័ព្ទដៃម៉ាក NOKIA ម៉ូដែល C5-03 ចំនួន ០១ គ្រឿង ។/

សាលក្រមនេះជំនុំជម្រះជាសាធារណៈនាថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១៥ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារសិទ្ធិជនជាប់ចោទ ប្រកាសជាសាធារណៈនៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ។ រក្សាសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។/.

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០១៥

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner